E314/11

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 11 / 2014
ម៉ោង (Time/Heure): 15:03
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **ឆ្វ មណី** ជាប្រធាន
ចៅក្រម **Rowan DOWNING**
ចៅក្រម **Chang-ho CHUNG**
ចៅក្រម **ហួត វុទ្ធី**
ចៅក្រម **ប្រាក់ គឹមសាន**

កាលបរិច្ឆេទ: ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចលើសំណើបន្ទាន់បង្ខំពាក់ព័ន្ធនឹងបណ្តឹងជិតចិត្ត

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

01036582

E314/11

**ក្រុមប្រឹក្សាជំនុំជម្រះពិសេស** នៃអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ក្រុមប្រឹក្សាជំនុំជម្រះពិសេស") បានទទួលសំណើបន្ទាន់បង្ខំមួយចំនួនទាក់ទងនឹងពាក្យបណ្តឹងរបស់មេធាវីការពារក្តី ខៀវ សំផន និង នួន ជា ដែលប្តឹងចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូងមិនឱ្យជំនុំជម្រះទៅលើសំណុំរឿង ០០២/០២ (ពាក្យបណ្តឹងជិតចិត្តរបស់ ខៀវ សំផន និង នួន ជា)[1]។ បច្ចុប្បន្ននេះ សំណើទាំងនេះកំពុងត្រូវបានដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះពិសេស ដែលសំណើសុំទាំងនោះ រួមមាន៖ ក/ សំណើសុំបង្កើនចំនួនទំព័រកំណត់របស់មេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ (សំណើរបស់ នួន ជា សុំបង្កើនចំនួនទំព័រកំណត់)[2] ខ/សំណើសុំបង្កើនចំនួនទំព័រកំណត់ និងសុំការអនុញ្ញាតដើម្បីឆ្លើយតបតែមួយភាសាជាមុនសិន របស់ការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព) ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ (សំណើរបស់ ក.ស.ព សុំបន្ថែមចំនួនទំព័រ និងដាក់ឯកសារតែមួយភាសា)[3] គ/ សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំផ្អាកដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ និងសុំឱ្យមានសវនាការផ្ទាល់មាត់មួយ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ (សំណើរបស់ ខៀវ សំផន សុំផ្អាកសំណុំរឿង ០០២/០២ និងសវនាការ)[4] និង ឃ/ សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ របស់មេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ (សំណើរបស់ នួន ជា សុំឱ្យមានសវនាការ)[5]។

---

[1] សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ឯកសារ E314/1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤។ បណ្តឹងជិតចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ឯកសារ E314/6 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[2] អ៊ីម៉ែលរបស់ទីប្រឹក្សាច្បាប់របស់ក្រុមមេធាវីការពារក្តី នួន ជា ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤។

[3] សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រដើម្បីឆ្លើយតបទៅនឹងបណ្តឹងជិតចិត្តចៅក្រមរបស់ នួន ជា និងការអនុញ្ញាតដើម្បីឆ្លើយតបតែមួយភាសាជាមុនសិន ឯកសារ E314/7 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤។

[4] បណ្តឹងជិតចិត្តសាជាថ្មីប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូងដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២ ឯកសារ E314/8 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤។

[5] សំណើរបស់ នួន ជា សុំឱ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងជិតចិត្តចៅក្រម ឯកសារ E314/6/1 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤។

## ១. សេចក្ដីផ្ដើម

2. ដើម្បីពន្លឿនដំណើរការនីតិវិធីពាក់ព័ន្ធនឹងបណ្ដឹងជិតចិត្តរបស់ ខៀវ សំផន និង នួន ជា តាមការស្នើសុំរបស់ភាគី និងជាលក្ខខណ្ឌតម្រូវនៃផលប្រយោជន៍យុត្តិធម៌ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានជូនដំណឹងក្រៅផ្លូវការរួចហើយទៅភាគីអំពីសេចក្ដីសម្រេចផ្សេងៗរបស់ក្រុមប្រឹក្សាចំពោះសំណើបន្ទាន់បង្ខំរបស់ភាគី ហើយបានណែនាំថា ក្រុមប្រឹក្សានឹងចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរមួយនាពេលឆាប់ៗខាងមុខ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសូមផ្ដល់សេចក្ដីសម្រេចជាផ្លូវការទាំងនេះ នាពេលនេះ។

## ២. សំអាងហេតុ

### ក. សំណើបង្កើនចំនួនទំព័រដែលបានកំណត់

3. កាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្ដី នួន ជា បានស្នើសុំបង្កើនចំនួនទំព័រកំណត់រហូតដល់ចំនួន ៤៥ ទំព័រ ជាអតិបរមា សម្រាប់ពាក្យបណ្ដឹងជិតចិត្តនាពេលខាងមុខរបស់ពួកគេប្រឆាំងនឹង ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះ ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្ដារា មិនឱ្យបន្តជំនុំជម្រះទៅលើសំណុំរឿង ០០២[6]។ មេធាវី នួន ជា បានលើកឡើងថា បណ្ដឹងជិតចិត្តរបស់ខ្លួននឹងផ្អែកទៅលើ "មូលដ្ឋានជាច្រើន" និងមាន "ការយោងទៅភស្ដុតាងជាច្រើន"[7]។

4. មាត្រា ៥.១ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (សេចក្ដីណែនាំអនុវត្ត) បានចែងថា "ឯកសារដាក់នៅ [...] អង្គជំនុំជម្រះសាលាដំបូង មិនត្រូវលើសពី ១៥ ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ ៣០ ទំព័រជាភាសាខ្មែរ លើកលែងតែមានបញ្ញត្តិចែងផ្ទុយពីនេះ នៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ឬសេចក្ដីណែនាំអនុវត្តនេះ ឬបទបញ្ជាចេញដោយ អ.វ.ត.ក"។ មាត្រា ៥.៤ ចែងបន្ថែមទៀតថា "តាមការស្នើសុំរបស់ភាគីចូលរួម អង្គជំនុំជម្រះដែលពាក់ព័ន្ធ អាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស"។

---

[6] អ៊ីម៉ែលចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ របស់ទីប្រឹក្សារបស់ក្រុមមេធាវីការពារក្ដី នួន ជា ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង។

[7] ដូចខាងលើ។

5. កាលពីថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានជូនដំណឹងទៅមេធាវីការពារក្តី នួន ជា ថា ក្រុមប្រឹក្សាយល់ព្រមតាមសំណើបង្កើនចំនួនទំព័ររបស់មេធាវីហើយ[8]។ ដោយពិចារណាទៅលើលក្ខខណ្ឌដែលបានកំណត់នៅក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុងដែលថា ភាគីដែលដាក់បណ្តឹងជំទាស់ចំពោះតុលាការ "បង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃពាក្យបណ្តឹង" និង "មានភស្តុតាងបញ្ជាក់" ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា ជាការត្រឹមត្រូវ និងជាប្រយោជន៍នៃយុត្តិធម៌ ក្នុងការអនុញ្ញាតចំពោះសំណើសុំ អនុលោមតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តនោះ។

6. កាលពីថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ក.ស.ព បានស្នើសុំឱ្យបង្កើនចំនួនទំព័រដល់ ៣០ ទំព័រជាភាសាអង់គ្លេស ជាអតិបរមា សម្រាប់ចម្លើយតបចំពោះបណ្តឹងជំទាស់របស់ នួន ជា និងសុំការអនុញ្ញាតឱ្យដាក់ចម្លើយតបជាភាសាអង់គ្លេសជាមុនសិន ដោយឯកសារបកប្រែជាភាសាខ្មែរនឹងត្រូវបញ្ជូនទៅតាមក្រោយ[9]។ ក.ស.ព បានលើកឡើងថា សំណើទាំងនេះមានភាពសមស្របដោយសារតែចំនួនទំព័រច្រើននៃបណ្តឹងជំទាស់របស់ នួន ជា និង "ភាពស្មុគស្មាញផ្នែកអង្គហេតុ អង្គច្បាប់ អំណះអំណាងផ្នែកធម្មនុញ្ញ និងគោលនយោបាយសាធារណៈអន្តរជាតិ ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនោះ"[10]។

7. កាលពីថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានជូនដំណឹងក្រៅផ្លូវការទៅភាគីថា ក្រុមប្រឹក្សាយល់ព្រមតាមសំណើសុំបង្កើនចំនួនទំព័រ និងការសុំអនុញ្ញាតដើម្បីឆ្លើយតបតែមួយភាសាជាមុនសិន[11]។ ក្រុមប្រឹក្សាយល់ឃើញថា សំណើរបស់ ក.ស.ព សុំបង្កើនចំនួនទំព័រ មានភាពសមស្រប អនុលោមតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្ត ដោយសារតែតម្រូវការក្នុងការឆ្លើយតបទៅនឹងសារណាផ្សេងៗដែលមានចំនួនទំព័រច្រើនជាងចំនួនទំព័រដែលមានកំណត់នៅក្នុងមាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តនោះ និងដើម្បីធានានូវសមភាពរវាងគូភាគី។ ដោយពិចារណាឃើញថា រយៈពេលកំណត់ ១០ ថ្ងៃ អាចមានរយៈពេលខ្លីពេក

---

[8] អ៊ីម៉ែលចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៤ របស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនទីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់ក្រុមមេធាវីការពារក្តី នួន ជា។

[9] សំណើរបស់ ក.ស.ព សុំបន្ថែមចំនួនទំព័រ និងដាក់ឯកសារតែមួយភាសា។

[10] ដូចខាងលើ កថាខណ្ឌ ៦។

[11] អ៊ីម៉ែលចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ របស់ក្រឡាបញ្ជីនៃក្រុមប្រឹក្សាជំនុំជម្រះពិសេសផ្ញើទៅកាន់ភាគី។

សម្រាប់ឆ្លើយតបទៅនឹងសំណើដែលមានចំនួនទំព័រច្រើនជាពីរភាសានៅពេលតែមួយ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ថាជាការត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យដាក់ចម្លើយតបជាភាសាអង់គ្លេសជាមុនសិន ដោយដាក់ចម្លើយតបជាភាសាខ្មែរតាមក្រោយឱ្យបានឆាប់តាមតែអាចធ្វើទៅបាន អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្ត។

## ខ. **ការសំណើសុំផ្អាកកិច្ចនីតិវិធី និង សវនាការជាសាធារណៈ**

8. នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើមកក្រុមប្រឹក្សាជំនុំជម្រះពិសេស ដែលក្នុងសំណើនោះក្រុមមេធាវីបាន (i) ស្នើម្តងទៀតសុំផិតចិត្តចៅក្រម និងបញ្ចូលទឡ្ហីករណ៍ទាំងអស់ដែលលើកឡើងនៅក្នុងបណ្តឹងផិតចិត្តចៅក្រមរបស់ នួន ជា (ii) ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិសេសឱ្យពន្យារពេលការចាប់ផ្តើមកិច្ចនីតិវិធីក្នុងសំណុំរឿង០០២/០២ រហូតក្រោយពេលមានសេចក្តីសម្រេចលើបណ្តឹងផិតចិត្ត (iii) ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិសេសឱ្យស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់លើបណ្តឹងផិតចិត្តរបស់ ខៀវ សំផន[12]។ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់សំណើសុំឱ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងផិតចិត្តចៅក្រម។ ជាជម្រើសមួយទៀត ប្រសិនបើសំណើរបស់ខ្លួនសុំឱ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងផិតចិត្តចៅក្រម ត្រូវបានបដិសេធនោះ ក្រុមមេធាវីការពារក្តី នួន ជា ជម្រាបដល់ក្រុមប្រឹក្សាជំនុំជម្រះពិសេសនូវចេតនារបស់ខ្លួនក្នុងការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយតបរបស់ ក.ស.ព ដែល ដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤[13]។

9. នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានជូនដំណឹងក្រៅផ្លូវការដល់ភាគីថាសំណើរបស់ក្រុមមេធាវីការពារក្តីសុំឱ្យមានសវនាការផ្ទាល់មាត់ ត្រូវបានបដិសេធ[14]។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសយល់ឃើញថា ក្រុមមេធាវីការពារក្តី ខៀវ សំផន មិនបានកំណត់សិទ្ធិអំណាចណាមួយដែលក្រុមប្រឹក្សាជំនុំជម្រះពិសេសអាចមានក្នុងការចេញដីកាបែបនេះ

---

[12] បណ្តឹងផិតចិត្តសាជាថ្មីប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូងដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២ ឯកសារ E314/8 ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤។

[13] សំណើរបស់ នួន ជា សុំឱ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងផិតចិត្តចៅក្រម ឯកសារ E314/6/1 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤។

[14] អ៊ីម៉ែលចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ របស់ក្រឡាបញ្ជីនៃក្រុមប្រឹក្សាជំនុំជម្រះពិសេសផ្ញើទៅកាន់ភាគី។

ឡើយ។ ផ្ទុយទៅវិញ អនុលោមតាមវិធាន៣៤(៥) ចៅក្រមដែលកំពុងមានបញ្ហា "អាចបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់ចិត្ត" ។ ផ្អែកលើមូលដ្ឋាននេះ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសន្និដ្ឋានថា សំណើនេះមិនស្ថិតនៅក្នុងវិសាលភាពនៃយុត្តាធិការរបស់ខ្លួនទេ។

10. នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានជូនដំណឹងក្រៅផ្លូវការដល់ភាគីថា សំណើរបស់ក្រុមមេធាវីការពារក្តីសុំឱ្យមានសវនាការផ្ទាល់មាត់ ត្រូវបានបដិសេធ និងថាខ្លួននឹងចាត់ចែងនីតិវិធីដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរជាសាធារណៈវិញ[15]។ វិធានផ្ទៃក្នុងមិនតម្រូវ ឬមិនបានប្រមើលមើលនូវទឡ្ហីករណ៍ផ្ទាល់មាត់មុនពេលធ្វើសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រមទេ[16]។ ក្រុមប្រឹក្សាជំនុំជម្រះពិចារណាឃើញថា ខ្លួនបានទទួលព័ត៌មានគ្រប់គ្រាន់ហើយតាមរយៈសារណារបស់ភាគី ក្នុងការសម្រេចលើបញ្ហានេះដោយផ្អែកតែទៅលើសារណាជាលាយលក្ខណ៍អក្សរ ហើយថា តម្រូវការក្នុងការធានានូវតម្លាភាព និងសាធារណភាពនៃកិច្ចដំណើរការនីតិវិធីទាំងនេះ គឺត្រូវបានបំពេញគ្រប់គ្រាន់ហើយតាមរយៈការធ្វើឱ្យសាធារណជនចូលមើលសារណាជាលាយលក្ខណ៍អក្សរទាំងអស់បាន។ អនុលោមតាម មាត្រា៨.៤ នៃសេចក្តីណែនាំអនុវត្ត ក្រុមប្រឹក្សាជំនុំជម្រះពិសេសអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តី នួន ជា ឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព ដែលនៅពេលនោះមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ។ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបង្គាប់ថា ការឆ្លើយតប៖ (i) ត្រូវដាក់នៅថ្ងៃអង្គារ ទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ឬមុននេះ (ii) កំណត់តែទៅលើបញ្ហាថ្មីៗតែប៉ុណ្ណោះប្រសិនបើមាន ដែលបានលើកឡើងនូវក្នុងចម្លើយតបរបស់ ក.ស.ព ជាជាងលើកទឡ្ហីករណ៍សាជាថ្មីលើចំណុចដែលបានលើករួចហើយនៅក្នុងបណ្តឹងជំទាស់ចិត្តសំណៅដើម និង (iii) ត្រូវដាក់ជាភាសាអង់គ្លេស ហើយឯកសារបកប្រែជាភាសាខ្មែរ និង បារាំង នឹងដាក់តាមក្រោយ ។

[15] អ៊ីម៉ែលចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ របស់ក្រឡាបញ្ជីនៃក្រុមប្រឹក្សាជំនុំជម្រះពិសេសផ្ញើទៅកាន់ភាគី។

[16] វិធាន ៣៤(៧) នៃវិធានផ្ទៃក្នុង ក៏ស្នើថា ពាក្យបណ្តឹងជំទាស់ចិត្តចៅក្រមគួរតែសម្រេចដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ។

11. នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្តី នួន ជា បានជូនដំណឹងដល់ក្រុមប្រឹក្សាជំនុំជម្រះពិសេសថា ខ្លួនពុំមានបំណងដាក់ការឆ្លើយតបជាលាយលក្ខណ៍អក្សរឡើយ[17]។

**យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ ក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រេច ÷**

**យល់ព្រមតាម** សំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំបង្កើនចំនួនទំព័រ។

**យល់ព្រមតាម** សំណើរបស់ ក.ស.ព ស្នើសុំបង្កើនចំនួនទំព័រ និងដាក់តែមួយភាសា។

**បដិសេធ** សំណើរបស់ ខៀវ សំផន ស្នើសុំផ្អាកកិច្ចដំណើការនីតិវិធីនៃសំណុំរឿង០០២/០២។

**បដិសេធ** សំណើរបស់ ខៀវ សំផន និង នួន ជា សុំឱ្យមានសវនាការជាសាធារណៈ។

**កត់សម្គាល់ថា** ក្រុមមេធាវីការពារក្តី នួន ជា បានសម្រេចមិនដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព ទៅតាមពេលវេលាកំណត់សម្រាប់ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទេ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះពិសេស**

**និល ណុន**

[17] អ៊ីម៉ែលចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ របស់ទីប្រឹក្សាច្បាប់របស់ក្រុមមេធាវីការពារក្តី នួន ជា ផ្ញើជូនក្រឡាបញ្ជីនៃក្រុមប្រឹក្សាជំនុំជម្រះពិសេស។